ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Nov-2012, 15:44
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(១៦)
Case File/Dossier Nº. 002/19-09-2007-ECCC-TC/SC(16)

| | |
|---|---|
| នៅចំពោះមុខ: | **ចៅក្រម គង់ ស្រ៊ឹម ប្រធាន** |
| | **ចៅក្រម Agnieszka KLONOWIECKA-MILART** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម ម៉ុង មុន្នីចរិយា** |
| | **ចៅក្រម Florence Ndepele MUMBA** |
| | **ចៅក្រម យ៉ា ណារិន** |
| កាលបរិច្ឆេទ: | **ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២** |
| ភាសា: | **ខ្មែរ/អង់គ្លេស** |
| ចំណាត់ថ្នាក់ឯកសារ: | **សាធារណៈ** |

# ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ

| | |
|---|---|
| **<u>សហព្រះរាជអាជ្ញា</u>** | **<u>ជនជាប់ចោទ</u>** |
| ជា លាង | អៀង ធីរិទ្ធ |
| Andrew CAYLEY | |

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**<u>មេធាវីជនជាប់ចោទ</u>**

ផាត់ ពៅស៊ាង

Diana ELLIS, QC

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖

**ទទួលបាន** បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចស្ដីពីការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការបន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (“បណ្ដឹងសាទុក្ខភ្លាមៗ”)[1]។

**កត់សម្គាល់** សំណើរបស់មេធាវីការពារក្ដីដែលស្នើឡើងឱ្យអង្គជំនុំជម្រះតុលាការកំពូលបើកសវនាការផ្ទាល់មាត់មុននឹងសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ ដើម្បីឱ្យភាគីធ្វើការពិភាក្សាឱ្យបានលម្អិតលើបញ្ហាអង្គហេតុ និងអង្គច្បាប់នៃបណ្ដឹងសាទុក្ខភ្លាមៗនេះ[2]។

**ដោយពិចារណាឃើញថា** សវនាការនៃរឿងក្ដីនេះនឹងផ្ដល់នូវព័ត៌មានសំខាន់ៗសម្រាប់ធ្វើការសម្រេចលើបណ្ដឹងសាទុក្ខនេះ ដោយបានផ្ដល់ឱកាសដល់អង្គជំនុំជម្រះស្ដាប់នូវយោបល់របស់ភាគីនីមួយៗលើលក្ខខណ្ឌនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ហើយបានអនុញ្ញាតអង្គជំនុំជម្រះធ្វើការពិភាក្សាជាមួយ អៀង វិជីដាដែលជាអាណាព្យាបាលទូទៅលើជនជាប់ចោទ ដែលត្រូវបានជ្រើសតាំងដោយសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១២។

---

[1] បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការបន្ទាប់ពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១១, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារលេខ E138/1/10/1/1។

[2] សារណាតបរបស់មេធាវីការពារក្ដីទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការបន្ទាប់ពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ និងសារណាបន្ថែមរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២, ឯកសារលេខ E138/1/10/1/5/5 កថាខណ្ឌ ៨៧។

**ហេតុដូច្នេះសម្រេច:**

**កំណត់កាលបរិច្ឆេទ** សវនាការលើបណ្តឹងសាទុក្ខជាសាធារណៈនៅថ្ងៃ អង្គារ ទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ វេលាម៉ោង **៩:៣០ ព្រឹក** នៅក្នុងសាលសវនាការនៃ អ.វ.ត.ក។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**